ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៥៣

ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

សាលដីកា

លេខ: ១៩ "VIII"

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៦៦ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥១ ក្រII "រ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនជាប់ឈ្មោះ [redacted] គុណា ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរកសិ មានទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្នភូមិត្រើយ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] "រ"



Scanned with CamScanner

ម្ដាយឈ្មោះ [redacted] "វ" ប្រពន្ធឈ្មោះ [redacted] "វ" ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ **ឆបោក និងក្លែងលិខិតឯកសារសាធារណៈ** ប្រព្រឹត្តនៅភូមិត្រើយបឹង ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧ មាត្រា ៣៧៨ មាត្រា ៦២៦ និងមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធី ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។ (អ្នកប្ដឹងសាទុក្ខ)

មានលោក [redacted] គន់ ជាមេធាវីការពារ ។

**អំពីអង្គហេតុៈ**

កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ ឈ្មោះ [redacted] គុណ ភេទប្រុស អាយុ ៣៦ឆ្នាំ បានល្បួងលោមឈ្មោះ [redacted] សុទ្ធី ភេទប្រុស អាយុ៣១ឆ្នាំ យកលុយលើកទី១ ចំនួន ៥០.០០០$ លើកទី២ ចំនួន ២៨៨.១១០$ ។ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ ឈ្មោះ [redacted] គុណ បានដកប្រាក់ឈ្មោះ [redacted] សុទ្ធី សរុបទាំងអស់ចំនួន ៣៣៨.១១០$ ដោយ ហេ គុណ អះអាងថា យកលុយទាំងអស់ទៅទិញដីស្រែប្រាំងដែលមានទីតាំងនៅភូមិថ្មី និងភូមិឈើទាលភ្លោះ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្ដាល និងទីតាំងមួយកន្លែងទៀតនៅភូមិសំបួរ ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម តែតាមពិតឈ្មោះ [redacted] គុណ មានល្បិចបំណងទុច្ចរិតមកបោកបញ្ឆោតក្លែងបន្លំឯកសារថា ទិញដីស្រែប្រាំងដែលមានទីតាំងដូចរៀបរាប់ខាងលើ យកលិខិតទិញលក់ផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីក្លែងបន្លំឯកសារសាធារណៈ មកបង្ហាញឈ្មោះ [redacted] សុទ្ធី តែតាមពិតពុំមានទីតាំងណាមួយពិតប្រាកដទេ ពេលដែល [redacted] សុទ្ធី ចុះទៅពិនិត្យដីដីដែលមានទីតាំងខាងលើ ស្រាប់តែអាជ្ញាធរបានបញ្ជាក់ថាឈ្មោះអ្នកទិញលក់ខាងលើនេះសុទ្ធតែភូតភរបោកប្រាស់ទាំងអស់ ហើយឈ្មោះ [redacted] សុទ្ធី បានទាក់ទងឈ្មោះ [redacted] គុណ ជាច្រើនលើ ច្រើនសារ តែជននេះព្យាយាមគេចវេសមិនលើកទូរស័ព្ទ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៥៨ "ង" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ឱ្យជនជាប់ចោទឈ្មោះ [redacted] គុណ (អត្តសញ្ញាណខាងលើ) រួចផុត ពីបទៈ ឆបោក និងក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិត្រើយបឹង ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧ មាត្រា ៣៧៨ មាត្រា ៦២៦ និងមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ ។

ទុកសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៨ "ង" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៥១ ក្រII "រ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។ ចំពោះផ្នែកអាជ្ញាមិនអាចទទួលយកបាន ។

២-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃ១១ ខែមករា ឆ្នាំ២០១៨ របស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥៨ (ង) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ ។

៤-សាលដីកានេះ ជំនុំជម្រះជាសាធារណៈថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ។ បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១៦៦ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុទ្ធី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥១ ក្រII "រ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា ការសម្រេចរបស់សាលាឧទ្ធរណ៍បានបញ្ជាក់ក្នុងសំអាងហេតុត្រង់ចំណុចទី៣ ទី៤ រួចហើយ ។ អ្នកប្តឹងសាទុក្ខឈ្មោះ [redacted] សុទ្ធី ជាដើមបណ្តឹងរដ្ឋប្បវេណី ហេតុនេះយោងតាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមានលក្ខណៈត្រឹមត្រូវហើយ ។



Scanned with CamScanner

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥១ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

+លោក [redacted] គង់ ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានថា៖ ឈ្មោះ [redacted] គុណ មានគំនិតទុច្ចរិតដោយក្លែងបន្លំឯកសារ ហើយយកលិខិតទិញលក់ផ្ទេរសិទ្ធិមកបង្ហាញឈ្មោះ [redacted] សុទ្ធី ជាថ្នូរយកលុយចំនួន ៣៣៨.១១០$ ថាដាក់ឈ្មោះជាកម្មសិទ្ធិឱ្យឈ្មោះ [redacted] សុទ្ធី ។ បន្ទាប់មកឈ្មោះ [redacted] សុទ្ធី បានចុះទៅដល់ទៅតាំងដីស្រាប់តែអាជ្ញាធរបញ្ជាក់ថា ឈ្មោះអ្នកលក់នោះសុទ្ធតែជាការភូតភរ និងបោកប្រាស់ទាំងអស់ រួចកូនក្តីខ្ញុំបាទបានព្យាយាមទាក់ទងទៅឈ្មោះ [redacted] គុណ ជាច្រើនលើកច្រើនសារ តែជននេះព្យាយាមគេចវេសមិនលើកទូរស័ព្ទ ។

<u>សំណូមពរ:</u> សូមតុលាការមេត្តាសម្រេចបដិសេធចោលសាលដីកាសាលាឧទ្ធរណ៍ ហើយបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៦៦ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សាលាឧទ្ធរណ៍បានសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] គុណ រួចផុតពីបទ: ឆបោក និងក្លែងបន្លំឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិត្រើយបឹង ឃុំព្រៃព្នៅ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧, ៣៧៨, ៦២៦ និងមាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ ។ មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងសាទុក្ខមកតុលាការកំពូល ។ ករណីនេះ តុលាការកំពូលពិនិត្យឃើញថា ដោយអនុលោមតាមស្មារតីមាត្រា ៤០២ តុលាការកំពូលពុំអាចពិនិត្យ និងពិចារណាលើបណ្តឹងសាទុក្ខនេះបានទេ ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពុំមានមូលហេតុសមស្របតាមស្មារតីមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។



Scanned with CamScanner

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥១ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូច្នេះ
## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៦៦ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុទ្ធី ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥១ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner